ទស្សនៈអ្នកនិពន្ធ

វ៉ុលេ៣, លេខ៦, ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១

# បញ្ហានៃវ៉ាក់សាំង និងការចាក់វ៉ាក់សាំង៖ បើមិនជួយចែវ កុំយកដៃរាទឹក

បណ្ឌិត អ៊ុន ឃាង *

ដោយមើលឃើញពីគ្រោះថ្នាក់ជាក់ស្ដែង និងបច្ចុប្បន្នភាពនៃការរីករាលដាលជំងឺរាតត្បាតកូវីដ១៩ ក៏ដូចជាការពន្លឿនការអភិវឌ្ឍវ៉ាក់សាំង ខ្ញុំគិតថា ខ្ញុំពុំចាំបាច់ធ្វើអត្ថាធិប្បាយម្ដងទៀតលើបញ្ហានៃការចាក់វ៉ាក់សាំង និងថាតើវ៉ាក់សាំងមួយណាដែលប្រជាជនកម្ពុជាគួរតែទទួលនោះឡើយ។ អត្ថប្រយោជន៍នៃការចាក់វ៉ាក់សាំងគួរតែត្រូវបានបង្ហាញយ៉ាងច្បាស់ក្រឡែតរួចទៅហើយ។ ជាអកុសល នេះមិនមែនជាករណីសម្រាប់មនុស្សមួយចំនួនទេ។ បន្ទាប់ពីបានអានការអត្ថាធិប្បាយរបស់អ្នករិះគន់រដ្ឋាភិបាល និងមេដឹកនាំគណបក្សប្រឆាំងក្នុងប៉ុន្មានថ្ងៃចុងក្រោយនេះ បង្ខំឱ្យខ្ញុំបញ្ចេញយោបល់សារជាថ្មីម្ដងទៀតទៅលើបញ្ហាទាំងនេះ។ ការអះអាងនៃអ្នករិះគន់ទាំងនេះទៅលើវ៉ាក់សាំង និងការចាក់វ៉ាក់សាំង មានភាពផ្ទុយស្រឡះ ដោយពេលខ្លះគ្មានភាពត្រឹមត្រូវ និងប្រកបដោយភាពគ្រោះថ្នាក់ដើម្បីកេងចំណេញនយោបាយ និងលើកតម្កើងខ្លួនឯង។ អ្នកទាំងនោះ ក៏ធ្លាប់បានចោទសួរពីសុវត្ថិភាពរបស់វ៉ាក់សាំងដែលផលិតនៅចិន ដោយលើកឡើងថា "**រដ្ឋាភិបាលកម្ពុជា មានចេតនាយកពលរដ្ឋខ្លួន ធ្វើជាឧបករណ៍សាកល្បងវ៉ាក់សាំងដើម្បីផ្គាប់ចិត្តចិន**"។ នៅពេលដែលការអះអាងនេះ ត្រូវបានគេច្រានចោល អ្នករិះគន់ទាំងនេះ បានប្ដូរមកលើកឡើងនូវបញ្ហាមួយផ្សេងទៀតទៅលើប្រសិទ្ធភាពរបស់វ៉ាក់សាំងចិន។ ខណៈមនុស្សមួយចំនួនក្នុងចំណោមនោះ បានប្រឆាំងនឹងការចាក់វ៉ាក់សាំងកាតព្វកិច្ច សម្រាប់ក្រុមមនុស្សជាក់លាក់មួយចំនួន ដូចជាកម្មកររោងចក្រ អ្នកខ្លះទៀតក្នុងចំណោមនោះ បានប្រតិកម្មយ៉ាងហួសហេតុ ដោយថាប្រជាជនកម្ពុជា មិនគួរទទួលយកការចាក់វ៉ាក់សាំងរបស់ចិនតែម្ដង។ តាមទស្សនៈរបស់ពួកគេ ប្រជាជនកម្ពុជាគួរតែរង់ចាំការចាក់វ៉ាក់សាំង ដែលផលិតនៅបស្ចិមប្រទេស។ ការអះអាងទាំងនេះ គ្មានលក្ខណៈវិទ្យាសាស្ត្រទាល់តែសោះ និងមានភាពគ្រោះថ្នាក់ណាស់ចំពោះអាយុជីវិត និងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។

កម្រិតប្រសិទ្ធភាពនៃវ៉ាក់សាំងចិន (Sinovac និង Sinopharm) ត្រូវបានគេរកឃើញថា មានប្រសិទ្ធភាពទាបជាងវ៉ាក់សាំងដែលផលិតដោយ Pfizer, AstraZeneca, Moderna និង Johnson & Johnson។ **យ៉ាងណាក្ដី អត្រាប្រសិទ្ធភាពទាបជាង មិនមែនស្មើនឹង គ្មានប្រសិទ្ធភាព នោះទេ។** បើទោះបីវ៉ាក់សាំងចិន មិនអាចការពារអ្នកចាក់វ៉ាក់សាំងបានទាំងស្រុងពីការឆ្លងក៏ដោយ (ហើយក៏មិនទាន់មានវ៉ាក់សាំងណាមួយអាចធ្វើបានដូចនេះនៅឡើយដែរ) ការសិក្សាបែបវិទ្យាសាស្ត្របានបង្ហាញថា វ៉ាក់សាំង ជួយកាត់បន្ថយភាពធ្ងន់ធ្ងរនៃជំងឺ បង្ការការចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ និងមរណភាពក្នុងចំណោមអ្នកដែលបានចាក់វ៉ាក់សាំងចិន។ តាមពិតទៅ កម្រិតប្រសិទ្ធភាពនៃវ៉ាក់សាំងចិន គឺស្របទៅនឹងស្តង់ដាររបស់អង្គការសុខភាពពិភពលោក។

ការអះអាងថាកម្ពុជាគួរតែរង់ចាំទទួលវ៉ាក់សាំងរបស់បស្ចិមប្រទេស គឺជានយោបាយដែលគ្មានភាពប្រាកដនិយម និងជានយោបាយអត្តឃាត។ ដូចដែលខ្ញុំបានបញ្ចេញមតិនៅក្នុងការអត្ថាធិប្បាយរបស់ខ្ញុំកាលពីលើកមុន "បណ្ដាប្រទេសអ្នកមានបានបញ្ជាទិញជាមុននូវវ៉ាក់សាំងផលិតដោយ AstraZeneca,

*__លោកបណ្ឌិត អ៊ុន ឃាង__ គឺជាសាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រនយោបាយ នៅសាកលវិទ្យាល័យ Northern Illinois សហរដ្ឋអាមេរិក និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

© *រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។*

Pfizer និង Moderna។ ដូចនេះ វាត្រូវការពេលវេលាយូរណាស់ ទម្រាំវ៉ាក់សាំងទាំងនេះ អាចទៅដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាប្រទេសកម្ពុជា។ ហើយនៅពេលនោះទៀតសោត តម្លៃវ៉ាក់សាំង នឹងមានតម្លៃខ្ពស់ជាង បើប្រៀបធៀបនឹងវ៉ាក់សាំងដែលផលិតនៅប្រទេសចិន”។ តាមពិត នៅពេលដែលជំងឺកូវីដ១៩ កំពុងរាលដាលពាសពេញពិភពលោក វិសមភាពនៃវ៉ាក់សាំងបានលេចចេញយ៉ាងច្បាស់។ គេប៉ាន់ប្រមាណថា វាអាចចំណាយពេលប្រហែលពីរឆ្នាំទៀត ដើម្បីប្រទេសក្រីក្រអាចទទួលបានវ៉ាក់សាំងបង្ការជំងឺកូវីដ១៩ពេញលេញ។ ដោយអត្រានៃការឆ្លងរាលដាលក្នុងសហគមន៍នាពេលបច្ចុប្បន្ន និងភាពមានកម្រិតនៃប្រព័ន្ធសុខាភិបាលនៅកម្ពុជា ប្រទេសកម្ពុជាមិនមានលទ្ធភាពរង់ចាំបន្តទៀតឡើយ។ ប្រសិនបើគ្មានវិធានការបង្ការ និងការចាក់វ៉ាក់សាំងតឹងរឹងទេ ការកើនឡើងនៃការឆ្លងនឹងធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធសុខាភិបាលនៅកម្ពុជា។ គេអាចស្រមៃបានថា តើមានមនុស្សប៉ុន្មាននាក់នឹងត្រូវបាត់បង់ជីវិត ឬត្រូវក្លាយជាជនរងគ្រោះដោយសារវីរុសកូរ៉ូណា។ ដូចដែលពិភពលោកបានឃើញវីរុសនេះ បានវាយប្រហារសូម្បីតែនៅប្រទេសដែលមានឧស្សាហកម្មជឿនលឿន ដូចជាប្រទេសអ៊ីតាលី ដែលមនុស្សរាប់ពាន់នាក់បានស្លាប់ ដោយសារកង្វះគ្រែមន្ទីរពេទ្យ និងបំពង់ជំនួយដង្ហើម។

ការអះអាងដែលគ្មានការទទួលខុសត្រូវរបស់ក្រុមប្រឆាំង អាចបង្កឱ្យមានភាពស្ទាក់ស្ទើរក្នុងចំណោមប្រជាជនកម្ពុជាក្នុងការចាក់វ៉ាក់សាំង។ ភាពស្ទាក់ស្ទើរបែបនេះ អាចបង្កនូវអន្តរាយដល់គោលដៅនៃការបង្កើតប្រព័ន្ធភាពស៊ាំនៅក្នុងសហគមន៍។ ស្ថានភាពនេះ នឹងធ្វើឱ្យកាន់តែមានភាពធ្ងន់ធ្ងរនៃការរីករាលដាលយ៉ាងឆាប់រហ័សនៃការឆ្លងវីរុសបម្លែងថ្មីនៃជំងឺកូវីដ១៩ដែលកំពុងតែកើតមាន។ ការរាតត្បាតនៅក្នុងសហគមន៍កាន់តែធ្ងន់ធ្ងរ នឹងតម្រូវឱ្យមានការបិទខ្ទប់សហគមន៍ក្នុងរយៈពេលយូរ និងទ្រង់ទ្រាយធំ។ ស្ថានការណ៍ទាំងនេះ នឹងជំរុញឱ្យមានផលប៉ះពាល់លើសង្គម និងសេដ្ឋកិច្ចកាន់តែធ្ងន់ធ្ងរ ដែលឈានដល់ហានិភ័យលើកំណើនសេដ្ឋកិច្ចដែលប្រទេសកម្ពុជា ព្យាយាមសម្រេចបានក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះ។

បន្ទាប់ពីការអះអាងមិនពិតជុំវិញប្រសិទ្ធភាពវ៉ាក់សាំងចិន ត្រូវបានបកស្រាយ ក្រុមប្រឆាំងបានអំពាវនាវដល់ប្រជាជនកម្ពុជាឱ្យទទួលការចាក់វ៉ាក់សាំងចិន។ តើពួកគេចង់បានអ្វីឱ្យពិតប្រាកដ? ចម្លើយជាក់ស្តែងគឺថា ក្រុមប្រឆាំងបានបង្វែរចុះឡើង និងធ្វើឱ្យត្រឡប់ត្រឡិនលើបញ្ហាវ៉ាក់សាំង ដើម្បីស្វែងរកផលប្រយោជន៍នយោបាយ។ យុទ្ធសាស្ត្រនេះ បានបង្កើតភាពច្របូកច្របល់ និងការមិនទុកចិត្ត ក្នុងចំណោមប្រជាជនកម្ពុជា ដែលធ្វើឱ្យប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ក្នុងការដោះស្រាយវិបត្តិជំងឺរាតត្បាតនេះ។ នៅក្នុងយុគសម័យដែលព័ត៌មានក្លែងក្លាយ ត្រូវបានចែកផ្សាយបន្តយ៉ាងឆាប់រហ័ស តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមនានា ទស្សនៈផ្លាស់ប្តូរចុះឡើង ឬទស្សនៈត្រឡប់ត្រឡិន ដើម្បីកេងចំណេញប្រយោជន៍នយោបាយ គឺមានភាពគ្រោះថ្នាក់ណាស់ដល់សន្តិសុខជាតិ។ ក្នុងអំឡុងពេលឆ្លងរាលដាលនៃជំងឺរាតត្បាត ប្រទេសកម្ពុជាត្រូវការជំនួយច្រើនសន្ធឹកណាស់ តាមដែលអាចទទួលបានពីអ្នកគ្រប់គ្នា និងគ្រប់ទីកន្លែង។ ដូច្នេះហើយ មនុស្សដែលមានសុភនិច្ឆ័យ និងសមហេតុផលគួរតែចងចាំក្នុងចិត្តថា “**បើមិនជួយចែវ កុំយកដៃរាទឹក**”។

Cambodia Development Center
Cambodia Development Center (@cd.centerkh)
Cambodia Development Center (t.me/cdcenterkh)
Building E, University of Puthisastra, #55, Street 180-184, Sangkat Boeung Raing, Khan Daun Penh
info@cd-center.org | (+855) 10 950 456 www.cd-center.org
មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center